# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ឆ្នាំពីរពាន់ម្ភៃ ខែ ឧសភា ថ្ងៃទីបួន វេលាម៉ោងដប់ប្រាំ នាទីល្ងាចនៅ ក្រុមហ៊ុន ចុង ឆាវ អេនធើប្រាយ(ខេមបូឌា)អិលធីឌី មានបើកកិច្ចប្រជុំមួយស្តីពីការព្យួរការងារកម្មករនិយោជិតមួយចំនួន ដោយមូលហេតុកង្វះវត្ថុធាតុដើម ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ-១៩ និង គ្មានអ្នកបញ្ជាទិញ ។ការប្រជុំពិភាក្សានេះគឺក្រោមអធិបតីភាពលោកនាយក HSU NAI CHIEH ជានាយកក្រុមហ៊ុន។

<u>សមាសភាពចូលរួមប្រជុំមាន</u>

<u>១/ភាគីតំណាងរោងចក្រ</u>

១,លោក HSU NAI CHIEH ជានាយករោងចក្រ

២,លោកស្រី សួន ចាន់ណា ជា រដ្ឋបាល

៣,លោកស្រី វ៉ាន់ លីដា ជាអ្នកកត់ត្រា

<u>២/ភាគីខាងតំណាងកម្មករនិយោជិត</u>

១ លោក ភី ចិន្តា ជាប្រធានសហជីព

២ លោក ធូ ចាន់និស្ស័យ ជាអនុប្រធានសហជីព

៣ អ្នកស្រី ស៊ុន សោភា ជាលេខាសហជីព

៤ អ្នកស្រី កែវ លក្ខិណា ជាប្រតិភូបុគ្គលិក

៥ កញ្ញា ប៉ូ សារុធ ជាប្រតិភូបុគ្គលិក

៦ លោកស្រី តាំង សុខា ជាប្រតិភូបុគ្គលិក

៧ កញ្ញា សួន ឡៃ ជាប្រតិភូបុគ្គលិក

៨ លោក ស្រី ឈី សុខឈីន ជាប្រតិភូបុគ្គលិក

៩ កញ្ញា ខាំ ស្រីនាង ជាប្រតិភូបុគ្គលិក

១០ លោក ស្រី ផុំ សុខេន ជាប្រតិភូបុគ្គលិក

១១ កញ្ញា មួង សុខុន ជាប្រតិភូបុគ្គលិក

ក្រោយពីប្រជុំពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់រួចមកភាគីទាំងពីរបានឈានដល់ការព្រមព្រៀងគ្នាដូចខាងក្រោម:

១) ក្រុមហ៊ុន សម្រេចព្យួរ ការងារកម្មនិយោជិតចំនួន ៩៥៨ នាក់ ក្នុងរយៈពេល ២ ខែដោយគិតចាប់ពីថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០ ។

២) ក្នុងអំឡុងពេលនៃព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុននឹងផ្តល់នូវ ប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក សម្រាប់កម្មករនិយោជិតម្នាក់ៗ ក្នុង១ខែក្នុងនោះ៖

- ចំនួន ១០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃដល់ ១០ថ្ងៃ
- ចំនួន ២០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃដល់ ២០ថ្ងៃ
- ចំនួន ៣០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃដល់ ១ខែ

៣) ក្រុមហ៊ុន រក្សាទុកនូវ មុខងារ តួនាទី ភារកិច្ច និង កន្លែងធ្វើការ របស់បងប្អូនដែលបានព្យួរការងារនៅដដែល។

៤)ប្រសិនបើក្រុមហ៊ុន មានវត្ថុធាតុដើមចូលមកវិញ ក្រុមហ៊ុននឹងហៅកម្មករនិយោជិតមកធ្វើការជាធម្មតាវិញ ។

កិច្ចប្រជុំបានចប់សព្វគ្រប់នាវេលាម៉ោង១៥:៥៥នាទី នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃ ចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោកស័ក ពុទ្ធសករាជ ២៥៦៣

ភ្នំពេញ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០

បានឃើញនិងឯកភាព
សហជីប និង តំណាងកម្មករ

បានឃើញនិងឯកភាព
នាយកក្រុមហ៊ុន

CHANG LI YING

ភី ចិន្តា ធូ ចាន់និស្ស័យ ស៊ុន សោភា កែវ លក្ខិណា ប៉ូ សារុធ

តាំង សុខា សួន ឡៃ ឈី សុខឈីន ខាំ ស្រីនាង ធុំ សុខេន មួង សុខុន